

# សេចក្តីជូនដំណឹងអំពីការធ្វើជំរឿន



រដ្ឋាភិបាលជប៉ុននឹងធ្វើជំរឿននាថ្ងៃទី១ ខែតុលា ឆ្នាំ២០២០។

ចាប់ពីពាក់កណ្តាលខែកញ្ញា អ្នកធ្វើជំរឿននឹងចុះទៅតាមគេហដ្ឋានរបស់លោកអ្នក
ដើម្បីចែកឯកសារនៃការធ្វើជំរឿន។

លទ្ធផលនៃការធ្វើជំរឿននឹងត្រូវបានយកទៅប្រើប្រាស់សម្រាប់គោលនយោបាយដូចជា
ការអភិវឌ្ឍន៍ទីក្រុងដែលជនបរទេសងាយស្រួលរស់នៅជាដើម។

បុគ្គលដែលជាគោលដៅនៃការធ្វើជំរឿនគឺមិនទាក់ទងនឹងសញ្ជាតិឡើយ
គឺអ្នកដែលបានរស់នៅប្រទេសជប៉ុនលើសពី៣ខែ ឬអ្នកដែលមានគម្រោងស្នាក់នៅប្រទេសជប៉ុនលើសពី៣ខែ។

ដោយសារបុគ្គលដែលជាគោលដៅនៃការធ្វើជំរឿន មានកាតព្វកិច្ចឆ្លើយសំណួរ សូមឆ្លើយសំណួរកុំខាន។

ខ្លឹមសារនៃចំលើយនឹងត្រូវបានយកទៅប្រើប្រាស់សម្រាប់តែធ្វើស្ថិតិប៉ុណ្ណោះ
គឺមិនយកទៅប្រើក្នុងគោលបំណងសម្រាប់គ្រប់គ្រងអន្តោប្រវេសន៍
ឬសម្រាប់ការស៊ើបអង្កេតរបស់ប៉ូលិសជាដើមឡើយ។

ចំពោះការធ្វើជំរឿនអ្នកអាចឆ្លើយតាមអ៊ីនធើណេតបាន។
សូមមេត្តាឆ្លើយតាមអ៊ីនធើណេតអោយបានមុនថ្ងៃទី៧ ខែតុលា (ពុធ)។
※ការឆ្លើយតាមអ៊ីនធើណេតអាចធ្វើទៅបានជាភាសាជប៉ុន ភាសាអង់គ្លេស ភាសាចិន(អក្សរសម្រួល ឬអក្សរពេញ)
ភាសាកូរ៉េ ភាសាវៀតណាម ភាសាអេស្ប៉ាញ និងភាសាព័រទុយហ្កាល់។

ក្នុងករណីដែលមិនបានទទួលចំលើយគិតត្រឹមថ្ងៃទី៧ ខែតុលា (ពុធ)

អ្នកធ្វើជំរឿននឹងធ្វើការក្រើនរំលឹកអោយផ្តល់ចំលើយ។

ក្នុងករណីមានចម្ងល់អំពីខ្លឹមសារនៃការធ្វើជំរឿន ឬមិនបានទទួលឯកសារនៃការធ្វើជំរឿន
សូមទាក់ទងទៅលេខទូរស័ព្ទផ្តល់ព័ត៌មានសម្រាប់ការធ្វើជំរឿន។

គេហទំព័រសម្រាប់ការធ្វើជំរឿនឆ្នាំ២០២០

https://www.kokusei2020.go.jp/

សម្រាប់ការពន្យល់អំពីការធ្វើជំរឿនជាភាសាខ្មែរ លោកអ្នកអាចមើលបានតាមរយៈ URL ក្នុង QR កូដខាងក្រោម
ចាប់ពីថ្ងៃទី១ ខែកញ្ញា (អង្គារ)។
https://www.kokusei2020.go.jp/household/language/khmer.html

លេខទូរស័ព្ទផ្តល់ព័ត៌មានសម្រាប់ការធ្វើជំរឿន៖ 0570-07-2020
អំឡុងពេលនៃសេវាផ្តល់ព័ត៌មាន៖ ថ្ងៃ៧ ខែកញ្ញា (ច័ន្ទ) ～ ៣១ ខែតុលា (សៅរ៍)
ម៉ោងទទួល៖ ម៉ោង៨ ព្រឹក ～ ម៉ោង៩យប់
※ អ្នកទទួលទូរស័ព្ទឆ្លើយតបជាភាសាជប៉ុន ប៉ុន្តែក៏អាចឆ្លើយតបជាភាសាបរទេសបានដែរ។

国勢調査
2020

Statistics Bureau　Ministry of Internal Affairs and Communications　○○○○○Prefecture